# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## អនុស្សរណៈ នៃការយោគយល់
## រវាង តំណាងបុគ្គលិក សណ្ឋាគារ រ៉េស៊ីដង់ សុខា ភ្នំពេញ
## និង ក្រុមហ៊ុន សុខាអូតែល

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ រវាងប្រធានផ្នែកនៃសណ្ឋាគារ រ៉េស៊ីដង់សុខា ភ្នំពេញ (ពីនេះតទៅហៅថា "**តំណាងបុគ្គលិក**") និង ក្រុមហ៊ុនសណ្ឋាគារសុខាអូតែល (ពីនេះតទៅហៅថា "និយោជក")។

ដោយសារតែការផ្ទុះឡើងនូវជំងឺកូវីត ១៩ ដែលកំពុងតែឆ្លងរាលដាលយ៉ាងខ្លាំងនៅទូទាំងពិភពលោកនាពេលនេះ បានធ្វើឱ្យអាជីវកម្មសណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ ជួបប្រទះនូវការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរបំផុត។ ហេតុនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ និយោជក និង តំណាងបុគ្គលិក បានចរចានិងព្រមព្រៀងគ្នាដាក់ឱ្យបុគ្គលិកចំនួន ១២៥នាក់ (ស្រី ៥២នាក់) ក្នុងចំនួនបុគ្គលិកសរុបចំនួន ៦៧០នាក់ (ស្រី ២៧៨នាក់) ឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០២១ ដល់ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០២១។

ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោមៈ

- និយោជិតដែលត្រូវបានដាក់ឱ្យឈប់សម្រាកពីការងាររយៈពេល ៣០ ថ្ងៃ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះទេ នៅក្នុងកំឡុងពេលនៃការឈប់សម្រាកនេះ។
- អតីតភាពការងាររបស់និយោជិតដែលដាក់ឱ្យឈប់សម្រាកដោយឥតប្រាក់ឈ្នួល នឹងមិនត្រូវបានប៉ះពាល់ឡើយ។
- ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារសណ្ឋាគារមិនផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតឡើយ។
- បុគ្គលិកនិយោជិតទាំងអស់យល់ពីស្ថានភាពសេដ្ឋកិច្ច ដោយសារជំងឺសកល Covid-19 បុគ្គលិកទាំងអស់ព្រមព្រៀងមិនទទួលប្រាក់ឧបត្ថម្ភពីសណ្ឋាគារឡើយ។

ចំពោះនិយោជិតដែលត្រូវរក្សាទុកក្នុងចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនីមួយៗ សម្រាប់ធ្វើការពេញម៉ោង (៤ សប្តាហ៍ ក្នុងមួយខែ)៖

- និយោជិតធម្មតានឹងទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះ ១០០%។
- និយោជិតថ្នាក់ប្រធាន/អនុប្រធានផ្នែក នឹងទទួលបានប្រាក់ឈ្នួលចាប់ពី ៤៥%-៧៥% នៃប្រាក់ខែគោល និងប្រាក់ធានានុគ្រោះ ១០០% ។

រីឯ និយោជិត ថ្នាក់ក្រោមអនុប្រធាន/ប្រធានផ្នែក ដែលតម្រូវឱ្យធ្វើការ ទៅតាមការងារតម្រូវ នឹងទទួលបានប្រាក់ឈ្នួល ១០០% នៃប្រាក់ខែគោល និងប្រាក់ធានានុគ្រោះ ដោយគណនាទៅតាមចំនួនថ្ងៃធ្វើការជាក់ស្តែងរបស់និយោជិតនីមួយៗ។

SOKHA PHNOM PENH HOTEL
BRANCH OF SOKHA HOTEL CO.,LTD

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ២០២១ ដល់ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០២១។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មី ប្រសិនបើស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការយោគយល់នេះឡើងវិញ។

ដើម្បីជាសក្ខីភាពនៃការព្រមព្រៀង គូភាគីបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ពីខាងក្រោមនេះ៖

**ហត្ថលេខាភាគីតំណាងនិយោជក**

______________________

**ផ្លុង ច័ន្ទដារិទ្ធ**

**ហត្ថលេខាភាគីតំណាងនិយោជិត**

សួស វីណា ______________________

ទេព សីហា ______________________

វីល្យៀម ចុហ្គាណាថាន ______________________

ហូ កុកហ្វៃ ______________________

យាន សារុធ ______________________

រស់ ង៉ែត ______________________

ឡាយ សោភ័ណ ______________________

សុខ សូរិឌ្ឍី ______________________

រឿន សេងហាប់ ______________________